**គម្រោងបង្ហាញបច្ចេកវិទ្យា ដើម្បីបង្កើន ផលិតភាពជុំវិញតំបន់ទន្លេសាប**

# *បច្ចេកទេសបណ្តុះផ្សិតចំបើងតាមបែបចំហុយ*TSTD





*វដ្តជីវិតលូតលាស់របស់ផ្សិតចំបើង*

## ក-សេចក្តីផ្តើម

ការបណ្តុះផ្សិតចំបើង ផ្តល់ប្រភពចំណូលថ្មីជាប្រចាំ ដល់គ្រួសារ ដោយគ្រាន់តែចំណាយពេលទំនេរ និង ធនធានមានមួយចំនួនប៉ុណ្ណោះ ។ ទន្ទឹមនឹងការបណ្តុះផ្សិតកសិករអាចប្រកបមុខរបរ ឬ ការងារផ្សេងទៀតបាន ។ តាមបទពិសោធន៍បអនុវត្តកន្លងមក កសិករគ្រួសារមធ្យម មានគ្នា ៤នាក់ អាចរកប្រាក់ចំណូលបន្ថែមពីការបណ្តុះ ផ្សិតមួយរោង (ប្រហែល ១០០ ដុំកំប៉ុស្តិ៍) បាន ប្រមាណពី ២០ ទៅ ២៥ ម៉ឺនរៀល ក្នុង១សារ រយៈពេល ១ខែ ។ ប្រាក់ចំណូលនេះ នឹងកើនថែមទៀត ទៅតាមចំនួនដុំ និង ការបណ្តុះផ្សិតច្រើនរោង។

## ខ-វិធីបណ្តុះផ្សិតចំបើងនៅកម្ពុជា

នៅកម្ពុជា ការបណ្តុះផ្សិតចំបើង ធ្វើតាម ២ របៀប គឺ ៖
(១) ប្រើចំបើងដុតជារង ឬ ថ្នាលរួចហើយគ្របហាលថ្ងៃ
(២) ប្រើល្បាយចំហុយ និង ផ្អាប់ក្នុងរោងហាប់បិទជិត។

ក្នុងឯកសារណែនាំបច្ចេកទេសសម្រាប់កសិករនេះ យើងនឹងលើកយកមកបង្ហាញតែរបៀបទី ២ ប៉ុណ្ណោះ។ របៀប ទី២ នេះ អាចប្រើបណ្តុះផ្សិត បានពេញមួយឆ្នាំ ទោះបីជា រដូវវស្សា មានភ្លៀងជោគជាំ ក៏ដោយ។

## គ-លក្ខណៈ និង តម្រូវការលូតលាស់ផ្សិតចំបើង

ផ្សិតចំបើងត្រូវការលក្ខខណ្ឌអាកាសធាតុក្តៅ ហើយសើមសម្រាប់ការលូតលាស់របស់វា ។ កំដៅកើតមកពីកំប៉ុស្តិ៍កម្មរបស់ដុំល្បាយបណ្តុះ ជាមួយនឹងសំណើមសមស្រប ក្នុងកន្លែងហប់ ដែលផុតពីកំដៅ និង ពន្លឺថ្ងៃផ្ទាល់ខ្លាំង ។ ផ្សិតអាចលូតលាស់បានល្អ ដោយស្រូបយកសារធាតុចិញ្ចឹមពីល្បាយកំប៉ុស្តិ៍បណ្តុះ ដាក់ក្នុងកន្លែងមានកំដៅសមស្រប (ពី ៣៥ ទៅ ៣៨ អង្សារ)។

## ឃ-ដំហ៊ាន និងដំណើរការរៀបចំបណ្តុះផ្សិតចំបើង

ការបណ្តុះផ្សិតចំបើងបែបចំហុយនេះ មាន៦ ដំហ៊ាន គឺ៖

### *១.ការលាយល្បាយ និង រៀបចំដុំល្បាយកំប៉ុស្តិ៍*





វត្ថុធាតុដើម សម្រាប់ផ្សំលាយធ្វើល្បាយកំប៉ុស្តិ៍បណ្តុះផ្សិតចំបើង រួមមាន៖

ក-ចំបើង ឬ គល់កញ្ច្រាំង ១០០គីឡូក្រាម *(បើមាន លាយជាមួយ កំប្លោកក្រៀម កាកអំពៅ ដើមចេកហាន់ហាលក្រៀម សំបកដំឡូងមី សំបកសណ្តែកបាយ ស្នូលគ ឬ កំទេចស្នូលពោត សរុប ទាំងអស់ឲ្យបាន ១០០គីឡូ)។*

ខ-កន្ទក់ម៉ដ្ត ចំនួនពី ៨ ទៅ ១០គីឡូក្រាម
គ-ចុងអង្ករ (ឬ ម្សៅដំណើប ឬ ម្សៅពោត) ចំនួន ១គីឡូក្រាម
ឃ-កំបោរស ចំនួន០,៥ គីឡូក្រាម
ង-ជីអ៊ុយរ៉េ ចំនួន ០,៥ គីឡូក្រាម (លាយទឹកស្រោចលើល្បាយ) ឬ ជីលាមកសត្វកំប៉ុស្តិ៍ក្រៀម ពី ៥ ទៅ ១០គីឡូក្រាម។
ច-ទឹកស្អាតលាយល្បាយ (សំណើមពី ៦០ ទៅ ៧០%)។

ក្នុងការលាយល្បាយ ជាការល្អ ត្រូវលាយវត្ថុធាតុដើម (ក) (ឃ) និង (ច) ចូលគ្នាឱ្យសព្វល្អជាមុន រួចគ្របផ្អាប់ចោល រយៈពេល ពី ៥ ទៅ ៧ថ្ងៃ ទើបយកទៅលាយច្របល់គ្នានឹងវត្ថុធាតុដើមផ្សេងទៀត ឱ្យបានសព្វល្អសើមល្មម ។ សំណើមល្មមសមស្រប អាចកត់សំគាល់បាន តាមការយកល្បាយចំបើងលាយរួច មកពូត ឬ មួលមើលឱ្យមានលក្ខណៈ សើមជោគ តែមិនមានស្រក់ទឹកចុះ ។ ល្បាយលាយរួចនេះ ត្រូវគ្របផ្អាប់ទុក ពី ១២ ទៅ ២៤ម៉ោង ដើម្បីឱ្យវាទន់ចូលជាតិគ្នាល្អ មុននឹងយកទៅជាន់ពុម្ព និង ច្រកថង់ដាក់ចំហុយ (ឬ រៀបដាក់ធ្នើរ ក្នុងរោងបាញ់ចំហាយទឹកចូល)។